ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**...ឈប់ចំនួន ០៣ថ្ងៃ

-ថ្ងៃទី០៩ វិច្ឆិកា បុណ្យឯករាជ្យជាតិ..............................ឈប់ចំនួន ០១ថ្ងៃ

-ថ្ងៃទី២១-២២-២៣ វិច្ឆិកា ពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ
អកអំបុក..............................................ឈប់ចំនួន ០៣ថ្ងៃ

-ថ្ងៃទី១០ ធ្នូ ទិវាសិទ្ធិមនុស្ស....................................ឈប់ចំនួន ០១ថ្ងៃ

មាត្រា ២ .- ពេលវេលាឈប់ទាំងឡាយខាងលើ ដែលត្រូវចំថ្ងៃណាមួយនៃថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ (ថ្ងៃសៅរ៍ ឬ ថ្ងៃអាទិត្យ) ត្រូវបានអោយឈប់ចំនួន០១ថ្ងៃ នៃថ្ងៃបន្ទាប់ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនេះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវបានអនុញ្ញាតអោយឈប់បន្ថែមជាថ្នូរ គឺតែចំនួន ០១ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣ .- បទបញ្ញត្តិទាំងឡាយណាដែលអោយឃើញមានការផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការ នៃគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវទទួលអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៦៨ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំពិធីខួបឆ្នាំចាស់

## អន្តរជាតិ និង ជួយជនចាស់ជរា

***

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៩៩៧/១៩៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/៩៦/១៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

-យោងសេចក្តីសម្រេចរបស់គណៈកម្មាធិការអភិវឌ្ឍន៍សង្គម នៃអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៣ ខែ មិនា ឆ្នាំ ១៩៩៧

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

-បានការឯកភាពពីសម្តេចនាយករដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី១២ ខែ តុលា ឆ្នាំ១៩៩៨

## សំរេច

**មាត្រា ១ .-** បង្កើតគណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរា ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| ១-នាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ | ជា សហប្រធានកិត្តិយស |
| ២-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | ជា ប្រធាន |
| ៣-អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន | ជា អនុប្រធាន |
| ៤-អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | ជា អនុប្រធាន |
| ៥-អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | ជា អនុប្រធាន |
| ៦-តំណាងក្រសួងមហាផ្ទៃ | ជា សមាជិក |
| ៧-តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ជា សមាជិក |
| ៨-តំណាងក្រសួងធម្មការ និង សាសនា | ជា សមាជិក |
| ៩-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | ជា សមាជិក |
| ១០-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជា សមាជិក |
| ១១-តំណាងក្រសួងព័ត៌មាន | ជា សមាជិក |
| ១២-តំណាងគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ | ជា សមាជិក |
| ១៣-តំណាងគណៈកម្មការសមាគមជាតិកាកបាទក្រហមកម្ពុជា | ជា សមាជិក |

**មាត្រា ២ .-** គណៈកម្មាធិការនេះអាចមានទីប្រឹក្សាបច្ចេកទេសស្ម័គ្រចិត្តតាមការចាំបាច់ ដោយស្នើពីសមាគមមនុស្សចាស់នានានៅកម្ពុជា អង្គការមិនមែនរដ្ឋាភិបាលក្នុង និងក្រៅប្រទេស និងអង្គការអន្តរជាតិ ។

មាត្រា ៣ .- គណៈកម្មការនេះមានភារកិច្ចដូចតទៅ ៖

១-រៀបចំគោលនយោបាយជាតិ ដើម្បីលើកស្ទួយគុណភាពជីវភាពរបស់មនុស្សចាស់ ពិសេសជនចាស់ជរាអោយប្រសើរឡើង ។

២-រៀបចំទិវាមនុស្សចាស់អន្តរជាតិ ជារៀងរាល់ឆ្នាំ ដោយកំណត់យកថ្ងៃទី០១ ខែតុលា ។

៣-សហការសំរបសំរួលជាមួយស្ថាប័នជាតិ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្នុងនិងក្រៅប្រទេស និងសប្បុរសជននានា ដើម្បីចូលរួមឧបត្ថម្ភគាំទ្រដល់ជនចាស់ជរានៅកម្ពុជា ។

៤-លើកគំរោងថវិកាជាតិ ដែលស្ថិតក្នុងបន្ទុកផែនការថវិកាចំណាយរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន សំរាប់រៀបចំទិវាមនុស្សចាស់អន្តរជាតិជារៀងរាល់ឆ្នាំ និងសំរាប់បើកម្មវិធីសេវាកម្មផ្សេងៗដល់មនុស្សចាស់ ។

៥-បង្កើតអនុគណៈកម្មការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរាតាមខេត្ត-ក្រុង តាមការចាំបាច់ ។

មាត្រា ៤ .- សមាជិកនៃគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន ។

មាត្រា ៥ .- គណៈកម្មាធិការជាតិរៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរា ត្រូវកំណត់តួនាទីភារកិច្ចនៃតំណាងក្រសួង ស្ថាប័ន ដូចមានចែងក្នុងប្រការ១នៃអនុក្រឹត្យនេះ និងត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ប្រចាំនៅក្រសួងសង្គមកិច្ចការងារនិងអតីតយុទ្ធជន ដោយប្រើក្របខ័ណ្ឌមានស្រាប់ ដើម្បីជំនួយការក្នុងកិច្ចសហការសំរបសំរួល ដោះស្រាយរាល់ការងារដែលពាក់ព័ន្ធបញ្ហាជនចាស់ជរាកម្ពុជា និងដំណើរការរៀបចំទិវាមនុស្សចាស់អន្តរជាតិ ។ តួនាទី និងភារកិច្ចរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ ត្រូវកំណត់ដោយ គណៈកម្មាធិការជាតិ រៀបចំទិវាមនុស្សចាស់អន្តរជាតិ និងជួយជនចាស់ជរា ។ គណៈកម្មាធិការជាតិនេះ ត្រូវប្រើត្រា ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ដើម្បីដំណើរការ ។

មាត្រា ៦ .- បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៧ .- សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងគ្រប់អង្គការជាតិដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ៦៩ អនក្រ.បក

## ស្តីពី បមាណីយ និងការគ្រប់គ្រងសម្ភារៈកសិកម្ម

***

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រី ទី២

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ នស/រកត/០១៩៥/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ ជស/រកត/០៨៩៧/១៨៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

-តាមការអនុម័តរបស់គណៈរដ្ឋមន្ត្រីនា ថ្ងៃទី១៦ ខែ តុលា ឆ្នាំ ១៩៩៨

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានទិសដៅធានាអោយបាននូវគុណភាពខ្ពស់នៃសំភារៈកសិកម្មដើម្បីពង្រីង និង បង្កើននូវផលិតកម្មកសិកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់និងមាននិរន្តរភាព ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ការផ្តល់នូវបមាណើយសមស្រប ព្រមដោយយន្តការគ្រប់គ្រងត្រឹមត្រូវ អាចធានាការពារបាននូវផលប្រយោជន៍របស់អ្នកប្រើប្រាស់ អ្នកផលិត អ្នកនាំចូល និងអ្នកលក់រាយសំភារៈកសិកម្ម ក៏ដូចជាការការពារបរិស្ថានផងដែរ ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានវិសាលភាព លើសំភារៈកសិកម្ម ដែលរួមមាន : ជីគីមី ថ្នាំកសិកម្ម គ្រាប់ពូជដំណាំ បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និងចំណីបន្ថែម ដែលសុទ្ធតែជាកត្តាចំបងក្នុងការបង្កើនផលិភាពដំណាំ និងសត្វ ។

**មាត្រា ៣ .-**

និយមន័យនៃពាក្យដែលប្រើក្នុងអនុក្រឹត្យនេះមានដូចតទៅ ៖

**១-បមាណីយសំភារៈកសិកម្ម** : គឺ ជាកំរិតគុណភាពអប្បបរមា ដែលអាច ទទួលយកបាន នៃសំភារៈកសិកម្មដែលមានចែងក្នុងអនុក្រឹត្យនេះ ហើយដែលរួមមានយថាប្រភេទសំភារៈ និងវិធានការត្រួតពិនិត្យ គុណភាពដូចជា ការចុះបញ្ជីកា ការវេចខ្ចប់ ការដាក់ផ្លាក សញ្ញា ។ល។

**២-សំភារៈកសិកម្ម** : រួមមាន ជីគីមី ថ្នាំកសិកម្ម គ្រាប់ពូជ បំណែកពូជដំណាំ បសុឱសថ ចំណីសត្វ និងចំណីបន្ថែម ដែលប្រើក្នុងផលិតកម្មកសិកម្ម ។

**៣-ជីគីមី** : គឺជាសារធាតុចិញ្ចឹមទោល ឬសមាសទាំងឡាយប្រើដើម្បីបង្កើននូវភាពលូតលាស់ទិនផល និង គុណភាពរបស់ដំណាំ ។

**៤-កិច្ចចុះបញ្ជីកា** : គឺជាការផ្តល់លិខិតយល់ព្រមដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ចំពោះសំភារៈកសិកម្មណាមួយ សំរាប់ការធ្វើពាណិជ្ជកម្ម ការចែកចាយ និងការប្រើប្រាស់ក្នុងស្រុក ឬនាំចេញ ។ កិច្ចចុះបញ្ជីកាក៏ជាដំណើរការវាយតំលៃនិងទទួលយកនូវឯកសារ ដែលអះអាងអំពីប្រសិទ្ធភាព និងសុវត្ថិភាព នៃផលិតផលដែលបានស្នើសុំដូចជា ជីគីមី ឬថ្នាំកសិកម្ម ។

**៥-លិខិតអនុញ្ញាតធ្វើអាជីវកម្ម** : គឺជាលិខិតអនុញ្ញាត ផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនបុគ្គល ឬក្រុមហ៊ុន ដែលផលិត កែច្នៃ ផ្គត់ផ្គង់ លក់ដុំ វេចខ្ចប់ជាថ្មី ស្តុក នាំចូល និងឬ នាំចេញ សំរាប់ការធ្វើពាណិជ្ជកម្មសំភារៈកសិកម្ម ។

**៦-ការធានាគុណភាព** : គឺជាការធានារបស់អ្នកផលិតចំពោះសមាសភាព នៃផលិតផល ។

**៧-ធាតុចិញ្ចឹម** : គឺជាធាតុចាំបាច់សំរាប់ការលូតលាស់របស់ដំណាំ ដូចជា អាសូត (N) ផូស្វ័រ(P) ប៉ូតាស្យូម (K) និងធាតុដទៃ ទៀត ។

**៨-សំភារៈវេចខ្ចប់** : គឺជា ធុង ដប អំពូល កញ្ចប់ ថង់ ឬកាវ ដែលមានភាពជាប់មាំ សំរាប់ច្រក ខ្ចប់ ឬ ផ្ទុក និងអាចរក្សាគុណភាព សំភារៈកសិកម្ម ។

**៩-ផ្លាកសញ្ញា** : គឺជាអក្សរ ឬរូបសញ្ញា ដែលមើលឃើញ ច្បាស់នៅលើ ឬបិទភ្ជាប់ ទៅនឹងសំភារៈវេចខ្ចប់ នៃសំភារៈកសិកម្ម ។

**១០-ការវេចខ្ចប់ថ្មី** : គឺជាការផ្ទេរសំភារៈកសិកម្មពីសំភារៈវេចខ្ចប់ដើម ទៅក្នុងសំភារៈវេចខ្ចប់ផ្សេងទៀតដែលតូចជាងមុនសំរាប់លក់ ។

**១១-ជីគីមីក្លែងបន្លំ** : គឺជាជីគីមីដែលមានលាយឡំជាមួយអង្គធាតុដែលជាជីគីមី ហើយធ្វើអោយអត្រាធាតុចិញ្ចឹមថយចុះ និងមិនត្រឹមត្រូវទៅនឹងបរិមាណគីមីដែលបានកំណត់ ។

**១២-ជីគីមីអន់គុណភាព** : គឺជាជីគីមីដែលត្រឹមត្រូវតាមបរិមាណគីមីតែ ត្រូវបានបាត់បង់ធាតុចិញ្ចឹមដោយមូលហេតុ ឬ កត្តាផ្សេងៗ ដូចជាសើមដោយទឹក ឬជីគីមីដែលសេសសល់នៅបាតឃ្លាំង ។ល។

**១៣-ជីគីមីក្រៅបទដ្ឋានអនុញ្ញាត** : គឺជាជីគីមីដែលមិនឆ្លើយតបទៅនឹងបរិមាណគីមី ។

**១៤-ថ្នាំកសិកម្ម** : គឺជាអង្គធាតុពុល ឬអង្គធាតុសរីរៈចម្រុះ ឬ សមាស ប្រើសំរាប់ :

-កំចាត់ បំផ្លាញ ទាក់ទាញ ប្រមូល បណ្តេញ សត្វល្អិត កណ្តុរ ស្មៅចង្រៃ និងសរីរាង្គមានជីវិតដទៃទៀត ដែលជាកត្តាចង្រៃបំផ្លាញដំណាំ ឬ

-ធ្វើអោយធូរស្រាលជម្ងឺដំណាំ បង្កដោយផ្សិត បាក់តេរី ណេមាតូត និងវីរុស ឬ

-សំរបសំរួលដល់ការលូតលាស់របស់ដំណាំ ជំរុះស្លឹក ឬ សំងួតដើមរុក្ខជាតិ ។

**១៥-ធាតុសកម្ម** : គឺជាធាតុមួយផ្នែកនៃថ្នាំកសិកម្ម ដែលមានអំពើលើជីវិតសត្វ ឬរុក្ខជាតិ ។

**១៦-ថ្នាំកសិកម្មហាមឃាត់** : គឺជាថ្នាំកសិកម្ម ដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានហាមឃាត់មិនអោយប្រើប្រាស់ ។

**១៧-គ្រាប់ពូជ** : គឺជាគ្រាប់ប្រើសំរាប់សាបព្រួស ឬដាំដំណាំកសិកម្ម ប្រភេទផ្សេងៗ ដូចជាគ្រាប់ពូជដំណាំស្បៀង ដំណាំហូបផ្លែ ដំណាំបន្លែ ដំណាំឧស្សាហកម្ម។ល។

**១៨-បំណែកពូជដំណាំ** : គឺជាបំណែកនៃដំណាំ កសិកម្មផ្សេងៗ ប្រើសំរាប់ការដាំដុះ ដូចជា ដើម មើម ខ្នែង មែកសាក មែកផ្សាំ វល្លិ ។ល។

**១៩-គ្រាប់ពូជមានវិញ្ញាបនប័ត្រ** : គឺជាគ្រាប់ពូជដំណាំដែល ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានចេញវិញ្ញាបនប័ត្រទទួលស្គាល់ ។

**២០-គ្រាប់ពូជពាណិជ្ជកម្ម** : គឺជាគ្រាប់ពូជដំណាំគ្រប់ប្រភេទ ដែលមានគុណភាពសំរាប់ការដាំដុះ ហើយដែលបានចរាចរលក់ដូរ តែមិនឆ្លងកាត់ការធ្វើវិញ្ញាបនប័ត្រ ។

២១-ភាពសុទ្ធនៃគ្រាប់ពូជជីណាំ : គឺជាគុណភាពនៃពូជដំណាំដែលបានកំណត់ដោយមិនរាប់បញ្ចូលគ្រាប់ពូជស្មៅ និងអង្គធាតុផ្សេងទៀតដែលនៅលាយឡំ ។

២២-មសុខិសុង : គឺជាធាតុណាមួយ រួមមាន លម្បាយ ឬ ការផ្សំនៃឱសថមួយមុខ ឬច្រើនមុខ ក្នុងទំរង់ណាមួយសំរាប់ប្រើប្រាស់លើសត្វគ្រប់ប្រភេទ ដើម្បីព្យាបាលទ្រទ្រង់សុខភាព ឬបង្កើនផលិតភាពរបស់សត្វ ។

២៣-ចំណីសត្វ : គឺជាសការធាតុចិញ្ចឹមផ្សេងៗផ្តល់អោយសត្វសំរាប់ការទ្រទ្រង់ ការលូតលាស់ និងផលិតកម្មសត្វ ។

២៤-ចំណីបន្ថែម : គឺជាធាតុផ្សំដែលរួមមាន វិតាមីន អង់ទីប៊ីយូទិច ឬអង្គធាតុរ៉ែក្នុងទំរង់ផ្សេងៗសំរាប់ប្រើប្រាស់បន្ថែមទៅចំណីសត្វ ។

២៥-អាជីវកម្ម : មានន័យថា អ្នកនាំចូល អ្នកនាំចេញ អ្នកផលិត និងអ្នកលក់រាយ នូវសំភារៈកសិកម្ម ។

## ជំពូកទី២

## ជីគីមី

មាត្រា ៤ .-

ជីគីមីគ្រប់ប្រភេទដែលនឹងអាចដាក់លក់នៅព្រះរាជាណាចក្រកម្ពុជាបាន ត្រូវតែមានកិច្ចចុះបញ្ជីកានៅក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ទោះបីជីគីមីនោះបានមកពីការនាំចូល ឬការផលិតក្នុងស្រុកក៏ដោយ ។ ការសុំចុះបញ្ជីកា ជាបន្ទុករបស់អ្នកនាំចូល ឬអ្នកផលិតជីគីមីនោះ ។

មាត្រា៥ .-

រូបវន្តបុគ្គល ឬ នីតិបុគ្គល ឬក្រុមហ៊ុនណាដែលមានបំណងផលិត ឬនាំចូល ឬនាំចេញជីគីមី ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

មាត្រា ៦ .-

ជីគីមីដែលផលិតនាំចូល ឬលក់ក្នុងប្រទេសកម្ពុជា ត្រូវតែមានស្លាកសញ្ញាដែលមានចែងអំពីធាតុចិញ្ចឹមដូចគ្នាទៅនឹងការធានាគុណភាព ដែលបានចុះក្នុងបញ្ជីកា ។

មាត្រា ៧ .-

ជីគីមីដែលនឹងដាក់លក់ត្រូវច្រកក្នុងសំភារៈវេចខ្ចប់ដែលមិនរំហោតធ្លុះធ្លាយ ធន់នឹងអាកាសធាតុ មានភាពជាប់មាំល្អ ដើម្បីធានាគុណភាព ព្រមទាំងសុវត្ថិភាពដល់ការដឹកជញ្ជូន ស្តុក និង ប្រើប្រាស់ ។

ការវេចខ្ចប់ជាថ្មីក្នុងថង់តូចៗសំរាប់លក់ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៨ .-**

គ្រប់សំភារៈវេចខ្ចប់ ទាំងអស់ត្រូវមានផ្លាកសញ្ញា ដើម្បីផ្តល់ពត៌មានគ្រប់គ្រាន់ និងច្បាស់លាស់ ដល់អ្នកប្រើប្រាស់ជាភាសាខ្មែរ ស្របតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មិនអនុញ្ញាតអោយលក់នូវជីគីមីណាដែលគ្មានផ្លាកសញ្ញា ឬមានផ្លាកសញ្ញា តែមិនអាចអានបាន ។

**មាត្រា ៩ .-**

ហាមផលិត នាំចូល ស្តុក និងលក់នូវជីគីមីក្លែងបន្លំ ។

**មាត្រា១០ .-**

ការលក់ដូរជីគីមីក្រៅយថាប្រភេទ ឬជីគីមីអន់គុណភាពត្រូវមានការអនុញ្ញាតពី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ អំពីការធ្វើអាជីវកម្ម ជីគីមី ទាំងនោះ ។

## ជំពូកទី៣

## ថ្នាំ កសិកម្ម

**មាត្រា ១១ .-**

ហាមនាំចូល ផលិត លាយផ្សំ វេចខ្ចប់ លក់ដុំ ឬលក់រាយនូវថ្នាំកសិកម្មណាដែលមិនបានធ្វើការចុះបញ្ជីកា ឬពុំមានចែងក្នុងប្រកាសអនុញ្ញាតអោយប្រើប្រាស់ជាបណ្តោះអាសន្ន របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។

**មាត្រា ១២ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបាន កំពុង ឬ មានបំណងធ្វើអាជីវកម្មថ្នាំកសិកម្ម ត្រូវចុះបញ្ជីកា និង មានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ១៣ .-**

ថ្នាំកសិកម្ម ដែលត្រូវចុះបញ្ជីកានៅក្រសួងកសិកម រុក្ខាប្រមាញ់ និង នេសាទ មាន :

១- ថ្នាំកសិកម្ម ដែលកំពុងត្រូវបានចរាចរលក់ដូរក្នុងទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា តែពុំមាន ចែងក្នុងប្រកាសដែល អនុញ្ញាតអោយប្រើប្រាស់ជាបណ្តោះអាសន្ន របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ ។

២- ថ្នាំកសិកម្មដែលមានចែងក្នុងបញ្ជី អនុញ្ញាតអោយប្រើប្រាស់ដោយក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និង នេសាទ

៣- ថ្នាំកសិកម្មថ្មីដែលមិនស្ថិតក្នុងចំណាត់ថ្នាក់ទី១ អនុលោមតាមចំណាត់ថ្នាក់អង្គការ WHO ។

៤- ថ្នាំកសិកម្មដែលបានធ្វើការចុះបញ្ជីការួច តែបានប្តូររូបមន្ត ឬឈ្មោះពាណិជ្ជកម្ម ។

មាត្រា ១៤ .-

ថ្នាំកសិកម្ម ដែលស្ថិតក្នុងបញ្ជីហាមប្រើប្រាស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ថ្នាំកសិកម្មដែលបាននាំចូលដោយមិនមានការអនុញ្ញាត និងថ្នាំកសិកម្មដែលស្ថិតក្នុងចំណាត់ថ្នាក់ទី១ អនុលោមតាមចំណាត់ថ្នាក់អង្គការ WHO មិនអនុញ្ញាតអោយធ្វើការចុះបញ្ជីកាឡើយ ។ លើកលែងតែក្នុងករណីបន្ទាន់ ឬតំរូវការពិសេស ចំណាត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

មាត្រា ១៥ .-

បញ្ជីកាថ្នាំកសិកម្មមាន ៤បែប គឺ ៖

១ -<u>បញ្ជីកាបណ្តោះអាសន្ន</u> ៖ បញ្ជីកានេះត្រូវធ្វើចំពោះគ្រប់មុខថ្នាំកសិកម្មដែលមានចែងក្នុងប្រកាសអនុញ្ញាតអោយប្រើប្រាស់ជាបណ្តោះអាសន្នរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយដែលកំពុងត្រូវបានចរាចរលក់នៅតាមទីផ្សារ ។

២- <u>បញ្ជីកាស្ថិតក្នុងល័ក្ខខ័ណ្ឌ</u> ៖ បញ្ជីកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណាដែលត្រូវបានស្នើសុំចុះបញ្ជីកាលើកដំបូងតែត្រូវផ្តល់បន្ថែមនូវទិន្នន័យ ឬល័ក្ខខ័ណ្ឌចាំបាច់ដទៃទៀតតាមតំរូវការបច្ចេកទេស របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

៣- <u>បញ្ជីកាពេញលេញ</u> ៖ បញ្ជីកានេះត្រូវធ្វើចំពោះថ្នាំកសិកម្មណាដែលអ្នកសុំចុះបញ្ជីកាបានបំពេញនូវគ្រប់តំរូវការបច្ចេកទេស របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
វិញ្ញាបនប័ត្រចុះបញ្ជីកា ព្រមទាំងលេខបញ្ជីកានឹងត្រូវចេញជូនដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៤- <u>ការអនុញ្ញាតអោយប្រើសំរាប់ពិសោធន៍</u> ៖ គឺជាអនុញ្ញាត ដើម្បីនាំចូលថ្នាំកសិកម្មណាដែលមិនទាន់បានចុះបញ្ជីកា សំរាប់យកមកប្រើប្រាស់ក្នុងគោលបំណង សិក្សាស្រាវជ្រាវប៉ុណ្ណោះ ។
បញ្ជីកាបណ្តោះអាសន្ន និងបញ្ជីកាស្ថិតក្នុងល័ក្ខខ័ណ្ឌ នឹងត្រូវបានផ្ទេរចូលទៅបញ្ជីកា ពេញលេញក្នុងរយៈពេលមួយឆ្នាំក្រោយ ប្រសិនបើអ្នកស្នើសុំចុះបញ្ជីការបានបំពេញនូវគ្រប់តំរូវការបច្ចេកទេស របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
ការសុំពន្យារសំរាប់រយៈពេលមួយឆ្នាំអាចអនុញ្ញាតបានក្នុងករណីដែលមានមូលហេតុសមស្រប។

មាត្រា ១៦ .-សុពលភាពនៃបញ្ជីកាពេញលេញមាន រយៈពេល៣ឆ្នាំ ករណីដែលគ្មានការដកហូត ឬលុបចោលណាមួយ ។ ការអនុញ្ញាតជាថ្មីដែលមានរយៈពេលដូចគ្នា អាចនឹងទទួលបានក្រោយពីបានបង់ថ្លៃបញ្ជីកា និងផ្តល់ទិន្នន័យបន្ថែម ។ ការខកខានក្នុងការសុំចុះបញ្ជីកាជាថ្មី សុពលភាពនឹងត្រូវលុបចោលជាស្វ័យប្រវត្តិ ។

មាត្រា ១៧ .-

សោហ៊ុយសេវាក្នុងកិច្ចចុះបញ្ជី និងកិច្ចចុះបញ្ជីជាថ្មី ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ១៨ .-

គ្រប់បញ្ជីកាវេចខ្ចប់ថ្នាំកសិកម្មដែលនឹងនាំចូល ស្តុកទុក លក់ដុំ និងលក់រាយ ត្រូវមានផ្លាកសញ្ញា ជាភាសាខ្មែរដែលងាយយល់ ។

ទំរង់និងលក្ខណៈនៃផ្លាកសញ្ញាត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ១៩ .-

គ្រប់សំភារៈវេចខ្ចប់ថ្នាំកសិកម្ម ត្រូវឆ្លើយតបទៅនឹងបទោបករណ៍ ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២០ .-

ការវេចខ្ចប់ថ្មីនូវថ្នាំកសិកម្ម ត្រូវហាមឃាត់ ។ ការវេចខ្ចប់ថ្មី អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការច្រក ឬរំលែកថ្នាំកសិកម្មណាមួយទៅក្នុងដប ឬ ធុង ឬ សំភារៈវេចខ្ចប់ចំណីអាហារ ឬភេសជ្ជៈ ត្រូវហាមឃាត់ជាដាច់ខាត ។

មាត្រា ២១ .- ហាមធ្វើអាជីកម្មនូវថ្នាំកសិកម្មដែល :

-ក្លែងបន្លំ

-ខូចគុណភាព

-មានប្រភេទ ឬ បរិមាណធាតុសកម្ម ខុសពីប្រភេទ ឬបរិមាណធាតុសកម្មដែលបញ្ជាក់លើផ្លាកសញ្ញា ។

-ថ្នាំកសិកម្មដែលចែងក្នុងបញ្ជីកាស្ថិតក្នុងលក្ខខ័ណ្ឌ ។

មាត្រា ២២ .-

របៀប និងលក្ខខ័ណ្ឌទុកដាក់ថ្នាំកសិកម្ម ត្រូវកំណត់ដោយក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ទីតាំងឃ្លាំងទុកដាក់ថ្នាំកសិកម្មត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន ។

មាត្រា ២៣ .- រាល់ការបោះចោល ការបំផ្លាញចោល នូវសំណល់ ឬ សំភារៈវេចខ្ចប់ថ្នាំកសិកម្ម របស់អាជីវករ ត្រូវមានការអនុញ្ញាតពី ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយមានការឯកភាពពីក្រសួងបរិស្ថាន ។

**មាត្រា ២៤ .-**

ការធ្វើការផ្សព្វផ្សាយថ្នាំកសិកម្ម ទោះតាមមធ្យោបាយណាក៏ដោយ ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

អាចអនុញ្ញាតអោយធ្វើការផ្សាយពាណិជ្ជកម្មបាន ចំពោះតែថ្នាំកសិកម្ម ដែលបានចុះបញ្ជីការពេញលេញ រួចហើយ ។

## ជំពូកទី ៤

## គ្រាប់ពូជ និងបំណែកពូជដំណាំ

**មាត្រា ២៥ .-**

គ្រប់គ្រាប់ពូជ និងបំណែកពូជដំណាំ ដែលដាក់លក់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានលក្ខណៈស្របតាមបមាណីយគុណភាពដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ២៦ .-**

ការនាំចូលនូវគ្រប់គ្រាប់ពូជ ឬបំណែកពូជដំណាំមកក្នុងប្រទេសកម្ពុជា ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយត្រូវអនុវត្តតាមបទបញ្ញត្តិនៃការត្រួតពិនិត្យភូតគាមអនាម័យ ។

**មាត្រា ២៧ .-**

រូបវន្តបុគ្គល ឬនីតិបុគ្គល មានបំណងផលិតគ្រាប់ពូជ មានវិញ្ញាបនប័ត្រ ឬបំណែកពូជដំណាំ ដើម្បីធ្វើពាណិជ្ជកម្ម ត្រូវធ្វើការចុះបញ្ជីកា នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ហើយត្រូវអនុវត្តតាមបច្ចេកវិទ្យា ដែលបានណែនាំសំរាប់ការផលិត និងដំណើរការរៀបចំទុកដាក់គ្រាប់ពូជទាំងនោះ ។

**មាត្រា ២៨ .-** គ្រប់គ្រាប់ពូជដំណាំទាំងអស់ដែលដាក់លក់ ត្រូវវេចខ្ចប់ និងត្រូវមានផ្លាកសញ្ញាតាមបមាណីយ និងយថាប្រភេទ ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

## ជំពូកទី ៤

## បសុឱសថ ចំណីសត្វ និង ចំណីបន្ថែម

**មាត្រា ២៩ .-** បែបបទ និងល័ក្ខខ័ណ្ឌ ក្នុងផលិតកម្ម អាហរ័ណកម្ម នីហរ័ណកម្ម ពាណិជ្ជកម្ម និងបមាណីយគុណភាព បសុឱសថ ត្រូវកំណត់ដោយ ប្រកាសរួម របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងក្រសួងសុខាភិបាល ដោយអនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងឱសថ ។

**មាត្រា ៣០ .-**

ផលិតករ និងអាជីវករ ចំណីសត្វ និងចំណីបន្ថែម ត្រូវចុះបញ្ជីកាផលិតផលរបស់ខ្លួន នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៣១ .-**

ចំណីសត្វ និងចំណីបន្ថែម ដែលកើតក្នុងស្រុក នាំចូល នាំចេញ និងឆ្លងកាត់ក្នុងប្រទេស ត្រូវមានលក្ខណៈស្របតាមការចុះបញ្ជិការរួចហើយ ។

**មាត្រា ៣២ .-**

ចំណីសត្វ និងចំណីបន្ថែម ដែលដាក់លក់ត្រូវវេចខ្ចប់ ហើយត្រូវមានផ្លាកសញ្ញាជាភាសាខ្មែរជាចាំបាច់ ។ ទំរង់ និងលក្ខណៈនៃផ្លាកសញ្ញា ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**មាត្រា ៣៣ .-**

ហាមផលិត ឬ លក់ ស្តុក នូវបសុឱសថ ចំណីសត្វ និង ចំណីបន្ថែមក្លែងបន្លំ ក្រោមកំរិតបមាណហើយ ឬផុតកំណត់ប្រើប្រាស់ ។

## ជំពូកទី ៦

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៣៤ .-**

ការគ្រប់គ្រងសំភារៈកសិកម្ម ការណែនាំ និងការត្រួតពិនិត្យ ដែលពាក់ព័ន្ធទៅនឹងសំភារៈកសិកម្ម តាមការកំណត់នៃអនុក្រឹត្យនេះ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥ .-** ត្រូវផ្តន្ទាទោសពិន័យរដ្ឋបាលដូចខាងក្រោមនេះ :

១-ព្រមានជាលាយល័ក្ខអក្សរ និងឃាត់ទុកវត្ថុល្មើស ជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលណាដែលបានធ្វើអាជីវកម្ម សំភារៈកសិកម្មដែលមិនបានចុះបញ្ជីកាដូចមានចែងក្នុងមាត្រា៩. មាត្រា១១.មាត្រា១២. និងមាត្រា៣១ ។

២-ព្រមានជាលាយល័ក្ខអក្សរ និងបង្គំអោយធ្វើកិច្ចសន្យាកែតំរូវក្នុងរយៈពេល ៧ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មសំភារៈកសិកម្ម ដោយពុំមានលិខិតអនុញ្ញាត ធ្វើអាជីវកម្ម របស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុង មាត្រា៥ - មាត្រា ៧ - មាត្រា១៣- និងមាត្រា ២១ ។

ឃាត់ទុកវត្ថុល្មើសជាបណ្តោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការក្នុងករណីប្រព្រឹត្តល្មើសលើកទី២ ។

៣-ព្រមានជាលាយលក្ខណ៍អក្សរ និងឃាត់ទុកវត្ថុល្មើសជាបណ្ដោះអាសន្ន រួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលណាដែលបានធ្វើអាជីវកម្មសំភារៈកសិកម្មក្លែងបន្លំ ឬខូចគុណភាព ឬខុសពីការធានាគុណភាព ដែលបានចុះបញ្ជីកា ដូចមានចែងក្នុង មាត្រា៦ - មាត្រា ៩ - មាត្រា២២ - មាត្រា២៩ - មាត្រា ៣២ និងមាត្រា ៣៤ ។ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាស្ថាពរ ក្នុងករណីប្រព្រឹត្តល្មើសលើកទី២ ។

៤-ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្គាប់អោយធ្វើកិច្ចសន្យាកែតំរូវក្នុងរយៈពេល ១៥ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មសំភារៈកសិកម្ម ដោយបំពានលើបមាណីយនៃការវេចខ្ចប់ ដូចមានចែងក្នុង មាត្រា៨ - មាត្រា ១៩ - មាត្រា២០ - មាត្រា២៩ - និងមាត្រា ៣៣ ដកហូតលិខិតអនុញ្ញាតធ្វើ អាជីវកម្មជាស្ថាពរ ក្នុងករណីប្រព្រឹត្តល្មើសលើកទី២ ។

៥-ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្គាប់អោយធ្វើកិច្ចសន្យាកែតំរូវក្នុងរយៈពេល ៧ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានធ្វើអាជីវកម្មថ្នាំកសិកម្ម ដោយមិនធានាសុវត្ថិភាពក្នុងការទុកដាក់ បោះចោលកាកសំណល់ ឬ សំភារៈវេចខ្ចប់ ឬ ផ្សព្វផ្សាយថ្នាំកសិកម្ម ដោយពុំមានការអនុញ្ញាតពីក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា២៣ - មាត្រា ២៤ និងមាត្រា ២៥ ។ ដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្មជាបណ្ដោះអាសន្ន ក្នុងករណីប្រព្រឹត្តល្មើសលើកទី២ ។

៦-ព្រមានជាលាយលក្ខណ៍អក្សរ ហើយបង្គាប់អោយធ្វើកិច្ចសន្យាកែតំរូវក្នុងរយៈពេល ៧ថ្ងៃ ចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបាននាំចូល ឬផលិតគ្រាប់ពូជ មានវិញ្ញាបនប័ត្រ ឬបំរែបំរួលពូជដំណាំ ដោយពុំមានការអនុញ្ញាត ឬ ចុះបញ្ជីកានៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចមានចែងក្នុងមាត្រា២៧ និង មាត្រា ២៨ ។

ការផ្ដន្ទាទោសពិន័យរដ្ឋបាល តាមការកំណត់ខាងលើនេះ ជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

មាត្រា ៣៦ .- រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងធ្វើអាជីវកម្មសំភារៈកសិកម្មនាំចូលថ្មី ត្រូវសុំចុះបញ្ជីកាសំភារៈកសិកម្មនោះនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់ពីពេលអនុក្រឹត្យនេះចូលជាធរមាន ។

អាជីវករដែលមានសំភារៈកសិកម្មសល់ពីមុន និងកំពុងតាំងលក់នៅ តាមទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវសុំចុះបញ្ជីកាសំភារៈកសិកម្មទាំងនោះនៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្នុងរយៈពេល១ឆ្នាំ យ៉ាងយូរ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបញ្ញតិ ។ ក្នុងរយៈពេល

លើសពី១ឆ្នាំ ត្រូវត្រឡប់ទៅអោយរដ្ឋាករ តាមការកំណត់ ដូចមានចែងក្នុងមាត្រា៣៦ នៃ អនុក្រឹត្យនេះ ។

### ជំពូកទី ៩

### អវសានប្បញ្ញត្តិ

**មាត្រា ៣៧ .-** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨ .-** សហការដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ុង ហួត ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៧០ អនក្រ.បក

## ស្តីពីការកែសំរួលតំបន់នៃការគ្រប់គ្រងធនធានធម្មជាតិ ព្រែកទឹកសាប ក្រុងព្រះសីហនុ

***

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ និង ព្រះរាជក្រឹត្យលេខ នស/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យ លេខជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស-រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ